# KHMER - ខ្មែរ

## របៀបបោះឆ្នោតនៅក្នុងការបោះឆ្នោតជាទូទៅក្នុងរដ្ឋអូស្ត្រាលីខាងលិច

សូមសួរមន្ត្រីចាត់ចែងការបោះឆ្នោត (Polling Official):

- ប្រសិនបើលោកអ្នកត្រូវការជំនួយ
- ប្រសិនបើលោកអ្នកបានធ្វើខុស
- ប្រសិនបើលោកអ្នកពុំយល់អំពីសេចក្តីណែនាំទាំងនេះ ហើយត្រូវការកិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ (ប្រសិនបើមានទូរស័ព្ទសម្រាប់ផ្តល់ជូន)

**ការបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់លោកអ្នក**

មុននឹងលោកអ្នកទទួលបានសន្លឹកឆ្នោតរបស់លោកអ្នក មន្ត្រីចាត់ចែងការបោះឆ្នោតដែលអង្គុយនៅក្បែរតុនឹងសួរលោកអ្នកបីសំណួរ:

១. តើលោកអ្នកបានបោះឆ្នោតមុនពេល សម្រាប់ការបោះឆ្នោតនេះហើយឬនៅ ឬតើនៅថ្ងៃនេះលោកអ្នកបានបោះឆ្នោតរួចហើយឬ?

២. តើលោកអ្នកឈ្មោះអ្វី?

៣. តើលោកអ្នករស់នៅទីណា?

លោកអ្នកអាចប្រគល់ប័ណ្ណបោះឆ្នោត EasyVote របស់លោកអ្នកទៅឲ្យមន្ត្រីចាត់ចែងការបោះឆ្នោត ដែលមានឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នកបោះពុម្ពពីលើវា ដែលគេបានផ្ញើមកឲ្យលោកអ្នក។ ប្រសិនបើលោកអ្នកពុំមានប័ណ្ណបោះឆ្នោត EasyVote មកជាប់ជាមួយលោកអ្នកទេ លោកអ្នកអាចសរសេរឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នកលើសន្លឹកក្រដាស មួយ រួចប្រគល់វាទៅឲ្យមន្ត្រីចាត់ចែងការបោះឆ្នោត។

**ប្រសិនបើឈ្មោះរបស់លោកអ្នកពុំមានចុះនៅក្នុងបញ្ជីបោះឆ្នោត**

នៅក្នុងកាលៈទេសៈខ្លះ លោកអ្នកនៅតែអាចបោះឆ្នោតបានដដែល ក៏ប៉ុន្តែលោកអ្នកនឹងត្រូវបំពេញពាក្យប្រកាសជាផ្លូវការមួយ។ មន្ត្រីចាត់ចែងការបោះឆ្នោតនឹងជួយលោកអ្នកអំពីរឿងនេះ។

**ការបោះឆ្នោតនៅក្រៅមណ្ឌលបោះឆ្នោតរបស់លោកអ្នក**

ប្រសិនបើលោកអ្នកបោះឆ្នោតនៅតាមកន្លែងបោះឆ្នោតណាមួយ ដែលពុំមែននៅក្នុងមណ្ឌលបោះឆ្នោតរបស់លោកអ្នកទេ លោកអ្នកអាចបោះឆ្នោតតាមរបៀប ការបោះឆ្នោតជាអវត្តមាន។

ពេលនោះ មន្ត្រីចាត់ចែងការបោះឆ្នោតនឹងណែនាំលោកអ្នកទៅកាន់តុមួយផ្សេងទៀត ដែលលោកអ្នកនឹងត្រូវបានគេស្នើសុំឲ្យបំពេញពាក្យប្រកាសជាផ្លូវការមួយ មុននឹងលោកអ្នកបានទទួលសន្លឹកឆ្នោត។ ក្រោយពីបានបំពេញសន្លឹកឆ្នោតហើយដូចបានណែនាំ សូមយកសន្លឹកឆ្នោតទាំងនោះទៅឲ្យមន្ត្រីទទួលពាក្យប្រកាសជាផ្លូវការ (Declaration Official)។

**ប្រសិនបើលោកអ្នកបានធ្វើខុស**

ប្រសិនបើលោកអ្នកបានធ្វើខុស សូមកុំខ្វល់ព្រួយអ្វីឡើយ - សូមគ្រាន់តែយកសន្លឹកឆ្នោតរបស់លោកអ្នកទៅឲ្យមន្ត្រីចាត់ចែងការបោះឆ្នោត រួចស្នើសុំសន្លឹកឆ្នោតមួយទៀត - បន្ទាប់មកសូមចាប់ផ្តើមបំពេញម្តងទៀត។ ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីបោះឆ្នោត សូមគ្រាន់តែសួរមន្ត្រីចាត់ចែងការបោះឆ្នោតប៉ុណ្ណោះ។

**ប្រព័ន្ធបោះឆ្នោតរបស់យើងគឺសម្ងាត់** - គ្មានអ្នកណាទៀតនឹងដឹងថាលោកអ្នកបោះឆ្នោតឲ្យអ្នកណាឡើយ លើកលែងតែលោកអ្នកជ្រើសរើសប្រាប់គេឲ្យបានដឹង។

## របៀបបោះឆ្នោតសម្រាប់សភានីតិបញ្ញត្តិ

**សន្លឹកឆ្នោតពណ៌ស - សូមសរសេរដាក់លេខគ្រប់ទាំងប្រអប់។**

សូមសរសេរដាក់លេខគ្រប់ទាំងប្រអប់ ទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក។

ចាប់ផ្តើមពីលេខ 1 សម្រាប់បេក្ខជនដែលលោកអ្នកនិយមចូលចិត្តជាងគេ រួចមកសរសេរដាក់លេខ 2 សម្រាប់ជម្រើសបន្ទាប់របស់លោកអ្នក ហើយជាបន្តបន្ទាប់មក។ បន្តរហូតទាល់តែលោកអ្នកសរសេរដាក់លេខគ្រប់ទាំងប្រអប់។




## របៀបបោះឆ្នោតសម្រាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ

**សន្លឹកឆ្នោតពណ៌ផ្កាឈូក - វិធីពីរបែបដើម្បីបោះឆ្នោត។**

សម្រាប់សន្លឹកឆ្នោតពណ៌ផ្កាឈូក លោកអ្នកមានជម្រើសមួយ - សូមគូសសន្លឹកឆ្នោតរបស់លោកអ្នកនៅខាងឆ្វេង ឬនៅខាងស្តាំ - ក៏ប៉ុន្តែមិនត្រូវគូសយកទាំងពីរឡើយ។

**នៅខាងឆ្វេង** - សូមសរសេរដាក់លេខ 1 នៅក្នុងប្រអប់ខាងឆ្វេងសម្រាប់គណៈបក្ខ ក្រុម ឬបេក្ខជនដែលលោកអ្នកជ្រើសរើស។

ឬ

**នៅខាងស្តាំ** - សូមសរសេរដាក់លេខគ្រប់ទាំងប្រអប់ទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក ចាប់ពីលេខ 1 ទៅ រហូតទាល់តែលោកអ្នកសរសេរដាក់លេខគ្រប់ទាំងប្រអប់នៅខាងស្តាំ។

សូមកុំសរសេរដាក់លេខដូចគ្នាឲ្យសោះ។




សូមកុំប្រើគូសសញ្ញាធីក (√) សញ្ញាខ្វែង ឬទុកប្រអប់ឲ្យនៅទំនេរ បើពុំដូច្នោះទេនោះ គេនឹងមិនរាប់សន្លឹកឆ្នោតរបស់លោកអ្នក ឡើយ។ ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីបំពេញសន្លឹកឆ្នោតរបស់លោកអ្នក សូមគ្រាន់តែសួរមន្ត្រីចាត់ចែងការបោះឆ្នោតប៉ុណ្ណោះ។